**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ: ៣០៤៥ មស.ស៨ណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចាក់វ៉ាក់សាំងកូវីដ-១៩(អាស្ត្រាហ្សេនីកា) ដូសជំរុញ ឬដូសទី៣ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការថ្នាក់ជាតិ នៃក្រសួងមុខងារសាធារណៈ

យោងសេចក្តីជូនដំណឹងលេខ៥៧៣/២១គ.វ.ក-១៩ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២១ របស់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស ស្តីពី ការចាក់វ៉ាក់សាំងកូវីដ-១៩ (អាស្ត្រាហ្សេនីកា) ដូសជំរុញ ឬដូសទី៣ នៅរាជធានីភ្នំពេញ នោះ តំណាងឱ្យអនុគណៈកម្មការចាក់វ៉ាក់សាំងកូវីដ-១៩របស់ក្រសួងមុខងារសាធារណៈ ខ្ញុំសូមជម្រាបជូនដំណឹងដល់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា** ថ្នាក់ជាតិរបស់ក្រសួងដែលបានចាក់វ៉ាក់សាំងស៊ីណូហ្វាម ឬស៊ីណូវ៉ាក់ ដូសទី១ និងដូសទី២រួចរាល់ ហើយមានគន្លាតរយៈពេល ៦ខែ ទៅ ៨ខែ បន្ទាប់ពីដូសទី១ មេត្តាជ្រាបថា ការចាក់វ៉ាក់សាំងកូវីដ-១៩ (អាស្ត្រាហ្សេនីកា) ដូសជំរុញ ឬដូសទី៣ នឹងប្រព្រឹត្តទៅ**ចាប់ពីម៉ោង ០៨:០០នាទី ដល់ម៉ោង១១:០០នាទីព្រឹក និងចាប់ពីម៉ោង១៤:០០នាទី ដល់ម៉ោង១៧:០០នាទី** ទៅតាមថ្ងៃខែឆ្នាំ និងទីកន្លែងកំណត់ដូចខាងក្រោម៖

**១. ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១**

- **មន្ទីរពេទ្យកាល់ម៉ែត** សម្រាប់ចាក់ជូនឥស្សរជនដែលមានតួនាទីជារដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬមានឋានៈស្មើ
- **មន្ទីរពេទ្យព្រះអង្គឌួង** សម្រាប់ចាក់ជូនឥស្សរជនដែលមានតួនាទីជាអនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង ឬមានឋានៈស្មើ

**២. ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២១**

- **មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក** សម្រាប់ចាក់ជូនមន្ត្រីរាជការដែលមានតួនាទីចាប់ពី ប្រធាននាយកដ្ឋានចុះ និងមន្ត្រីជាប់កិច្ចសន្យា

ឯកសារដែលត្រូវយកទៅជាមួយមានដូចខាងក្រោម៖

- ប័ណ្ណចាក់វ៉ាក់សាំងកូវីដ-១៩
- ប័ណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ ឬប័ណ្ណសម្គាល់មន្ត្រីជាប់កិច្ចសន្យា
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារប្រើប្រាស់ក្នុងការចុះឈ្មោះចាក់វ៉ាក់សាំងដូសទី១

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដូសជំរុញ ឬដូសទី៣ ដូចបានកំណត់ខាងលើឱ្យបានគ្រប់គ្នា។

ថ្ងៃ ពុធ ៣កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០២១
**រដ្ឋលេខាធិការ**
**ប្រធានអនុគណៈកម្មការចាក់វ៉ាក់សាំងកូវីដ-១៩**
**របស់ក្រសួងមុខងារសាធារណៈ**

**អែម ប៊ុនថុល**